ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ : ០៤ សរ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ១៩៩៤

# សារាចរ

## ស្តីពីក្របខ័ណ្ឌសមត្ថកិច្ចក្នុងការសំរេចរបស់ ប្រធាន ក្រសួងស្ថាប័ន

យោងតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ រាជរដ្ឋាភិបាលបានសង្កេតឃើញថា កន្លងមកមានក្រសួងស្ថាប័នមួយចំនួន បានធ្វើការសំរេចដោយខ្លួនឯងក្នុងការចេញលិខិតបទដ្ឋាន មានលក្ខណៈមិនសមស្របទៅនឹងច្បាប់និងគោលការណ៍របស់រាជរដ្ឋាភិបាល ដែលជាហេតុនាំអោយមានឥទ្ធិពលមិនល្អដល់ការដឹកនាំគ្រប់គ្រងរបស់រាជរដ្ឋាភិបាលព្រមទាំងធ្វើអោយប៉ះពាល់ខូចខាតដល់ផលប្រយោជន៍ជាតិទៀតផង ។

ដើម្បីរក្សាបាននូវប្រសិទ្ធភាពដឹកនាំព្រមទាំងការពារបាននូវផលប្រយោជន៍ជាតិនិងពង្រឹងនូវវិន័យការងាររបស់សមាជិករាជរដ្ឋាភិបាល រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួងស្ថាប័នដូចខាងក្រោមនេះ :

១-ប្រធានក្រសួងស្ថាប័ននិមួយៗ ត្រូវប្រតិបត្តិអោយបានត្រឹមត្រូវតាមក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ក្នុងច្បាប់ ក្នុងការសំរេចលើកិច្ចការនិមួយៗ ពោលគឺត្រូវសំរេចអោយស្របតាមច្បាប់តាមគោលការណ៍របស់រាជរដ្ឋាភិបាល និង ជៀសវាងមិនអោយជាន់ការកិច្ចសិទ្ធិអំណាចរបស់ក្រសួងស្ថាប័នដទៃឡើយ ។

២-ក្នុងករណីមានការសំរេច ដែលហួសពីក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងស្ថាប័នខ្លួន ប្រធានក្រសួងស្ថាប័ននោះត្រូវតែសុំការអនុញ្ញាតិពីរាជរដ្ឋាភិបាលជាមុន ជាអាទិ៍ដូចជាការចរចារឬចុះហត្ថលេខាលើអនុសញ្ញា កិច្ចព្រមព្រៀង ពិធីសារ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស សន្តិសុខ និងការពារប្រទេស ជាមួយបណ្តាប្រទេសនានា ជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ឬជាមួយក្រុមហ៊ុននានា ត្រូវសុំការអនុញ្ញាតិ និងត្រូវមានការប្រគល់សិទ្ធិពីរាជរដ្ឋាភិបាលជាមុន ។ ការសំរេចក្នុងការតែងតាំងផ្លាស់ប្តូរ ឬ បញ្ឈប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទក្រសួងស្ថាប័នក៏ត្រូវអនុវត្តអោយបានត្រឹមត្រូវ

តាមនិតិវិធី ដែលបានកំណត់ក្នុងច្បាប់ជាធរមាន ។ល ។

៣-រាល់លិខិតបទដ្ឋានរបស់ក្រសួងស្ថាប័នដែលមានលក្ខណៈផ្ទុយពីសេចក្តីណែនាំនេះ ត្រូវបានចាត់ទុកជានិរាករណ៍ ។

ក្រោយពេលទទួលបានសារាចរនេះប្រធានក្រសួងស្ថាប័នទាំងអស់ចំណុះរាជរដ្ឋាភិបាល ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ។

| | | |
|---|---|---|
| <u>កន្លែងទទួល ៖</u> | **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| -ខុទ្ទកាល័យព្រះមហាក្សត្រ | | |
| -អគ្គលេខាធិការដ្ឋានរដ្ឋសភា | | |
| -គ្រប់ក្រសួងស្ថាប័ន | **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |
| -កាលប្បវត្តិ - ឯកសារ | | |